ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ

-លេខ ៣៦៩ (ស)

-ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២២

-សំណុំរឿងព្រហ្មទណ្ឌលេខ ៣៣៥៣

ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២១

-សំណុំរឿងស៊ើបសួរលេខ ២៦៧៩

ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២១

-សំណុំរឿងជំនុំជម្រះលេខ ៥០១២

ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២១

តាចនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២២ វេលាម៉ោង ០៩ ព្រឹក ដោយមានសមាសភាព៖

ចៅក្រមជំនុំជម្រះ

-លោកស្រី [redacted] ជាអនុប្រធានសាលាដំបូងរាជធានីភ្នំពេញ

តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

ក្រឡាបញ្ជីសវនាការ

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

លើសំណុំរឿងព្រហ្មទណ្ឌលេខ: **៣៥៣៣** ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២១ ដែលមានជនជាប់ចោទ៖

-ឈ្មោះ [redacted]**ថារ៉ា** ភេទប្រុស អាយុ ៣០ឆ្នាំ ជនជាតិខ្មែរ មុខរបរបើកឡានក្រុមហ៊ុន ទីកន្លែងកំណើត[redacted] ក្រុងភ្នំពេញ អាសយដ្ឋានបច្ចុប្បន្នស្នាក់នៅផ្ទះ[redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted]**អ៊ីវ** (រស់) ម្តាយឈ្មោះ [redacted]**ចាន់ស៊ីថា** (រស់) ប្រពន្ធឈ្មោះ [redacted] ពេជ្រចន្ទា (រស់) មានកូន ០២ នាក់ ជានីតិជន ទោសពីមុនគ្មាន។ (ក្រៅឃុំ)

ជាប់ចោទពីបទ: **គំហែងយកទ្រព្យ** (ច្រវាក់) ប្រព្រឹត្តនៅចំណុចបន្ទប់ជួលភូមិដំណាក់ដំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៦៣ និងមាត្រា ៣៦៤ នៃក្រមព្រហ្មទណ្ឌ។

-មេធាវី [redacted]

អត្តលេខ ១២៧៨, មេធាវី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted]**ថារ៉ា**។

អង្គហេតុនៃរឿងមានដូចតទៅ៖

កាលពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១ វេលាម៉ោងប្រមាណ២៣ និង៣០នាទី នៅចំណុចបន្ទប់ជួលភូមិដំណាក់ធំ៣ សង្កាត់ស្ទឹងមានជ័យ៣ ខណ្ឌមានជ័យរាជធានីភ្នំពេញ មានជនសង្ស័យឈ្មោះ [redacted]**ថារ៉ា** ភេទប្រុស អាយុ៣០ឆ្នាំ និងបក្ខពួក បានស្លៀកពាក់ស៊ីវិលមានប្រើវិទ្យុទាក់ទងបិទឡូហ្គោអាវុធហត្ថទៅចុះចាប់ករណីគ្រឿងញៀនហើយបាននាំក្មេងប្រុសម្នាក់ដែលមានគ្រឿងញៀនមួយកញ្ចប់តូចកាន់នៅដៃទៅចង្អុលបង្ហាញជនរងគ្រោះនៅក្នុងបន្ទប់ជួលខាងលើហើយឈ្មោះ [redacted]**ថារ៉ា** និងបក្ខពួកបានធាក់ទ្វារបន្ទប់ជួលជនរងគ្រោះឈ្មោះ [redacted]**កុសល ហៅស្វិត** ដើម្បីឆែកឆេររកគ្រឿងញៀនតែឆែកឆេររកមិនឃើញក៏យកគ្រឿងញៀនពីក្មេងម្នាក់នោះ ឱ្យម្ចាស់អ្នកជួលបន្ទប់កាន់ថែមទាំងបានថតរូបជាភស្តុតាងហើយគំរាមកំហែងទារប្រាក់ចំនួន

៥០០ (ប្រាំរយ) ដុល្លារអាមេរិក។ ជនរងគ្រោះឈ្មោះ [redacted] កុសលហៅស្វិតភ័យក៏បានសុំអង្វរទៅជនជាប់ចោទឈ្មោះ [redacted]ថារ៉ា និង បក្ខថាសុខចិត្តយកម៉ូតូទៅបញ្ចាំតាមការទារប្រាក់របស់ជនជាប់ចោទ និងបក្ខពួកបន្ទាប់ពីបានប្រាក់រួចជនជាប់ចោទ និងបក្ខពួកក៏បានរត់គេចខ្លួនបាត់។ បន្ទាប់មកជនរងគ្រោះក៏បានហៅអ្នកកាសែតLive ថាមានអាវុធហត្ថបានមកគំរាមទារប្រាក់ពីខ្លួនចំនួន ៥០០ ដុល្លារអាមេរិកចោទថាខ្លួនមានគ្រឿងញៀនក្នុងបន្ទប់ទើបសមត្ថកិច្ចកងរាជអាវុធហត្ថខណ្ឌមានជ័យបានធ្វើការស្រាវជ្រាវរកជនសង្ស័យ និងឃាត់ខ្លួនជនសង្ស័យឈ្មោះ [redacted]ថារ៉ាបានតែម្តង។

-**បានឃើញ** របាយការណ៍សរុបលេខ ១៣៥/២១ រ.ប.ក ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២១ របស់ការិយាល័យព្រហ្មទណ្ឌ នៃកងរាជអាវុធហត្ថរាជធានីភ្នំពេញ។

-**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ២៧៣៥ អ.យ.ជ ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** ដីកាសន្និដ្ឋានស្តាពរលេខ ៣៧៤៣ អ.យ.ជ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-**បានឃើញ** ដីកាបញ្ជូនរឿងទៅជំនុំជម្រះលេខ ៥១៩៤ (ច)ដ.ដ ចុះថ្ងៃទី០៤ ខែវិច្ឆិកាឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ។

ឆាពេលសវនាការ

-ជនរងគ្រោះឈ្មោះ [redacted] **ណោត** បានឆ្លើយថា: កាលពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១ វេលាម៉ោង ២៣ និង ៣០ នាទី នៅចំណុចបន្ទប់ដែលខ្លួនជួលស្នាក់នៅខណៈដែលខ្លួន និងប្តីកំពុងដេកក្នុងបន្ទប់ ស្រាប់តែមានក្មេងប្រុសម្នាក់មកគោះទ្វារបន្ទប់របស់ខ្លួន ព្រមជាមួយគ្នានោះក៏មានជនមួយក្រុមមានគ្នាប្រហែល ០៧ នាក់ (ប្រុស) បានធាក់ទ្វារបន្ទប់ខ្លួនទម្លុះចូល និងសុំឆែកឆេរ ដែលនៅក្នុងចំណោមនោះខ្លួនបានឃើញក្មេងប្រុសម្នាក់ជាប់ខ្មោះផងដែរ ហើយក្នុងជនមួយក្រុមនោះ ខ្លួនបានស្គាល់ចំនួន ០៣ នាក់ រួមមានឈ្មោះ [redacted] **ឈឿន** (សន្តិសុខយាមផ្ទះជួលនោះ) ឈ្មោះ **ភ័ក្រ** (សន្តិសុខផ្ទះជួលនោះ) និងឈ្មោះ **រ៉ា** ភេទប្រុស ស្លៀកពាក់ស៊ីវិល (តាំងខ្លួនជាអាវុធហត្ថ)។ បន្ទាប់មកឈ្មោះ **រ៉ា** បានបញ្ជាឱ្យឈ្មោះ **ភ័ក្រ** ដាក់ខ្មោះប្តីរបស់ខ្លួនឈ្មោះ [redacted] **កុសល** ហើយរុញចេញក្រៅបន្ទប់ រួចយកក្រាមពណ៌សផ្ការួយកញ្ចប់តូចចេញពីហោប៉ៅខោក្មេងប្រុសនោះមកដាក់នៅមុខប្តីរបស់ខ្លួន និងឱ្យប្តីខ្លួនកាន់ថែមទាំងថតរូបទុកជាភស្តុតាង។ ក្រោយមកឈ្មោះ រ៉ា បានបង្ខំពួកខ្លួនឱ្យរកលុយឱ្យគាត់ចំនួន ៥០០ ដុល្លារ ដើម្បីបញ្ចប់រឿងដោយគំរាមកំហែងថា បើមិនឱ្យលុយទេ គាត់នឹងយកប្តីខ្លួនដាក់គុក ពេលនោះខ្លួនគ្មានលុយទេ ប៉ុន្តែដោយសារខ្លួនភ័យខ្លាចខ្លាំងពេក ខ្លួនក៏យល់ព្រមឱ្យពួកគាត់ (ឈ្មោះ រ៉ា និងបក្ខពួក) ជូនខ្លួនយកម៉ូតូរបស់ខ្លួនម៉ាកហុងដា សេ១២៥ ពណ៌ខ្មៅ ស្លាកលេខ ភ្នំពេញ ៩៣៣៤ ទៅបញ្ចាំនៅម្តុំផ្សារឃ្លាំងរំសេវ ហើយខ្លួនត្រូវបានបង្ខំឱ្យចូលទៅបញ្ចាំយកប្រាក់ចំនួន ៦៦០ ដុល្លារ សរុបទាំងការប្រាក់។ ក្រោយពេលបញ្ចាំម៉ូតូបានប្រាក់ឈ្មោះ **រ៉ា** និងឈ្មោះ **ភ័ក្រ** បានយកប្រាក់រួចក៏ប្រគល់ប្រាក់ឱ្យខ្លួនចំនួន ១០០ ដុល្លា ដើម្បីបង់ថ្លៃផ្ទះជួល ហើយបង្គាប់ឱ្យពួកខ្លួនរើតវ៉ាន់ចេញពីបន្ទប់ជួលឱ្យឈប់ជួលនៅទីនោះ បន្ទាប់មកពួកគាត់ក៏ជិះម៉ូតូភីស៊ីអិច គេចខ្លួនបាត់ដោយបន្សល់ទុកនូវម៉ូតូមួយគ្រឿងម៉ាកអឺមអេសអិច។ ចំពោះឈ្មោះ [redacted] **ឈឿន** នៅពេលគាត់បានចូលរួមឆែកឆេរបន្ទប់ដែរនោះ គាត់ពុំបានគំរាមកំហែង និងគំរាមយកប្រាក់ពីខ្លួនឡើយ។

-ជនជាប់ចោទឈ្មោះ [redacted]**ថារ៉ា** បានឆ្លើយថា: ខ្លួនមិនមែនជាមន្ត្រី ឬបានតាំងខ្លួនជាមន្ត្រីកងរាជអាវុធហត្ថនោះទេខ្លួនជាពលរដ្ឋធម្មតាប៉ុណ្ណោះ។ ខ្លួនមិនកំហែងយក(ប្រាក់) ពីជនរងគ្រោះនៅចំណុចបន្ទប់ជួលភូមិដំណាក់ធំសង្កាត់ស្ទឹងមានជ័យ

ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៥ខែសីហាឆ្នាំ២០២១ ដូចការចោទប្រកាន់របស់តំណាងអយ្យការទេ។ រឿងហេតុដែលកើតឡើងដូចក្នុងកំណត់ហេតុចម្លើយដែលខ្លួនបានឆ្លើយនៅចំពោះមុខមន្ត្រីកងរាជអាវុធហត្ថរាជធានីភ្នំពេញចុះថ្ងៃទី ៣០ ខែសីហា ឆ្នាំ២០២១ ខ្លួនរក្សាដដែលមិនកែប្រែទេហើយគ្មានការគំរាមកំហែងនិងវាយបង្ខំឲ្យផ្តល់ចម្លើយដែរ។ ខ្លួនមិនបានប្រើប្រាស់គ្រឿងញៀនទេ។ ខ្លួនមិនដែលប្រើព្រឹត្តអំពើនេះទេកន្លងមកជាលើកទី១ដែលរូបខ្លួនត្រូវបានគេចោទប្រកាន់ថាបានគំរាមកំហែងយកប្រាក់តែខ្លួនពិតជាមិនបានប្រព្រឹត្តទេ។ ឈ្មោះលឿនភេទប្រុសអាយុប្រហែល៤៥ឆ្នាំ, ឈ្មោះ **ភ័ក្រ** ភេទប្រុស អាយុប្រហែល៣៧ឆ្នាំ ជាសន្តិសុខយាមនៅបន្ទប់ជួល ភូមិដំណាក់ធំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ មិនមែនជាមិត្តភក្តិខ្លួនទេ ហើយរាប់អានគ្នា៧ ទៅ៨ខែ ហើយមូលហេតុដែលស្គាល់ខ្លួនដោយសារខ្លួនចេញពីបំរើការងារបើកឡាន ឲ្យខាងធនាគារស្ថាបនាពេលល្ងាចៗក៏ទៅលេងនៅម្តុំនោះដែលម្ចាស់ផ្ទះជួលជាមិត្តភក្តិ ហើយក៏ស្គាល់សន្តិសុខពីរូបនេះ។ ពេលស្គាល់ឈ្មោះ **លឿន**, ឈ្មោះ **ភ័ក្រ** ខ្លួនមិនបានពិភាក្សារៀបចំគំរោង ឬដើម្បីរួមគ្នាទៅប្រព្រឹត្តអំពើឈ្មើសអ្វីនោះទេ។ ចំពោះជនរងគ្រោះជាប្តីប្រពន្ធនៅក្នុងរឿងខ្លួនមិនដែលស្គាល់ឬមានគំនុំអ្វីជាមួយគ្នាទេ។ ជនរងគ្រោះជាប្តីប្រពន្ធនៅក្នុងរឿងខ្លួនគ្រាន់តែដឹងថាបានជួលបន្ទប់ស្នាក់នៅកន្លែងកើតហេតុភូមិដំណាក់ធំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។ ហើយកន្លងមកម្ចាស់ផ្ទះជួលតែងពឹងខ្លួនឲ្យមើលការខុសត្រូវនិងជួយណែនាំកុំឲ្យ! អ្នកជួលបន្ទប់ប្រើប្រាស់ឬលក់ដូរគ្រឿងញៀននៅទីតាំងបន្ទប់ជួលនេះ។ នៅវេលាម៉ោង១១:៣០យប់ថ្ងៃទី២៥ខែសីហាឆ្នាំ២០២១មានមនុស្សប្រុសម្នាក់មិនស្គាល់ឈ្មោះពាក់អាវ ខ្មៅវាលភ្លៀកដើរចូលមកបន្ទប់ជួលកន្លែងកើតហេតុហើយសន្តិសុខឈ្មោះ លឿន, ឈ្មោះ ភ័ក្រ រួមទាំងរូបខ្លួនដែលយាមនៅទីតាំងកន្លែងកើតហេតុនេះឃើញ ក៏ដេញតាមចាប់បានឆែកឃើញកញ្ចប់បារី១ ក្នុងនោះមានកញ្ចប់គ្រឿងញៀន១កញ្ចប់ ខ្លួនក៏សួរថាបានមកពីណា? យកទៅណា? បុរសមិនស្គាល់ឈ្មោះនោះប្រាប់ថាយកមកពីឈ្មោះ **ស្វិត** ហើយប្រាប់ថាយកទៅឲ្យគេ និងប្រាប់ទៀតថាបន្តិចទៀតមានគេមកយកនៅក្រៅរបងបន្ទប់ជួលហើយ។ ខ្លួន និងសន្តិសុខឈ្មោះ **លឿន**, ឈ្មោះ **ភ័ក្រ** ក៏នាំបុរសមិនស្គាល់ឈ្មោះទៅបន្ទប់ជួលរបស់ឈ្មោះស្វិតស្នាក់នៅដើម្បីសាកសួរបុរសមិនស្គាល់ឈ្មោះអះអាងថាខ្លួនបានទិញថ្នាំញៀនពីឈ្មោះ**ស្វិត**ទើបពួកខ្លួនសម្រេចនាំបុរសមិនស្គាល់ឈ្មោះទៅបន្ទប់ជួលរបស់ឈ្មោះស្វិតដើម្បីបញ្ជាក់ការពិត។ ពេលមកដល់បន្ទប់ជួលឈ្មោះស្វិតបានបដិសេធថាមិនបានលក់ថ្នាំញៀនឲ្យបុរសមិនស្គាល់ឈ្មោះនេះទេ។ នៅពេលនោះប្តីប្រពន្ធជនរងគ្រោះឈ្មោះ **ស្វិត** បានសំណូមពរកុំឲ្យមានរឿងពាក់ព័ន្ធលើការទិញលក់ថ្នាំញៀនបានសុំសំរួលផ្តល់ប្រាក់ឲ្យទៅពួកសន្តិសុខដែលយាមនៅបន្ទប់ជួលដែលពួកគេស្គាក់នៅពិតមែនតែខ្លួនមិនបានដឹងឮរឿងនេះទេ។ ចំពោះការដែលប្តីប្រពន្ធជនរងគ្រោះឈ្មោះ **ស្វិត** បានសំណូមពរកុំឲ្យមានរឿងពាក់ព័ន្ធលើការទិញលក់ថ្នាំញៀន បានសុំសំរួលផ្តល់ប្រាក់ឲ្យទៅពួកសន្តិសុខដែលយាមនៅបន្ទប់ជួលដែលពួកគេស្គាក់នៅពិតមែនតែខ្លួនមិនបានដឹងឮរឿងនេះទេ។ ចំពោះការដែលប្តីប្រពន្ធជនរងគ្រោះយកម៉ូតូទៅបញ្ចាំនៅម្តុំផ្សារឃ្លាំងរំសេវដើម្បីយកប្រាក់មកប្រគល់ឲ្យនោះគឺខ្លួនក៏មិនបានបង្គាប់បញ្ជាឲ្យរកប្រាក់មកផ្តល់ឲ្យនោះទេប្តីប្រពន្ធជនរងគ្រោះទេជាអ្នកនិយាយហើយអង្វរទៅពួកសន្តិសុខទាំងពីរនោះហើយបានជិះម៉ូតូទៅកន្លែងបញ្ចាំជាមួយឈ្មោះភ័ក្រតែម្តង។ ប្រាក់ដែលជនរងគ្រោះផ្តល់ឲ្យសន្តិសុខផ្តល់ឲ្យនោះខ្លួនមិនបានបង្ខិតបង្ខំ ឬ គំរាមកំហែងពួកគាត់ផ្តល់ប្រាក់មកឲ្យសន្តិសុខនិងខ្លួននោះទេ។ក្រៅពីរូបខ្លួននិងសន្តិសុខឈ្មោះ **លឿន**, ឈ្មោះ **ភ័ក្រ** ខ្លួនមិនមានបក្ខពួកផ្សេងទេ។ ក្នុងរឿងនេះខ្លួនមានសាក្សីឈ្មោះឃ្លោកភេទប្រុសអាចឆ្លើយបញ្ជាក់បាន។ ខ្លួនសូមពរសុំឲ្យលោកចៅក្រមធ្វើការដោះលែងបានត្រឡប់ទៅផ្ទះវិញសុំកែខ្លួនលែងប្រព្រឹត្តទៀតហើយ។

-តាមចម្លើយសាក្សីឈ្មោះ [redacted] **ហឿន ហៅតាឃ្លោក** បានឆ្លើយថា: ខ្លួនអ្នកទទួលបញ្ជើម៉ូតូនៅផ្ទះជួលកន្លែងកើតហេតុរយៈពេល៦ ឆ្នាំហើយ។ខ្លួនដឹងថាឈ្មោះលឿនភេទប្រុសអាយុប្រហែល៣៩ឆ្នាំ, ឈ្មោះ ភ័ក្រ ភេទប្រុស អាយុប្រហែល ៣៥ ឆ្នាំ ជាសន្តិសុខយាមនៅបន្ទប់ជួលភូមិដំណាក់ធំសង្កាត់ស្ទឹងមានជ័យខណ្ឌមានជ័យរាជធានីភ្នំពេញហើយនៅក្រុមហ៊ុន ๘

សន្តិសុខអីខ្លួនមិនដឹងទេ ហើយក៏មិនដឹងពីសាវតាជាតិរបស់អ្នកទាំងពីរដែរ។ ចំពោះឈ្មោះ [redacted] ថារ៉ាភេទប្រុសខ្លួនបានជួបមិនសូវញឹកញាប់ទេហើយមិនដែលមានទំនាក់ទំនងអ្វីជាមួយគ្នាទេ។ ខ្លួនតែងបានឃើញឈ្មោះ [redacted] ថារ៉ាភេទប្រុសដើរមើលការខុសត្រូវក្នុងផ្ទះជួលកន្លែងកើតហេតុមិនដឹងគាត់ធ្វើការងារអ្វីទេហើយក៏មិនដឹងថាត្រូវជាអ្វីជាមួយម្ចាស់បន្ទប់ជួលនោះទេ។ នៅពេលរឿងហេតុកើតឡើងកាលពីយប់ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១ នៅបន្ទប់ជួលភូមិដំណាក់ធំ សង្កាត់ស្នឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ខ្លួនមិនបានដឹងទេ។ នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២១ ម៉ោង៣ជាងរសៀលម្ចាស់បន្ទប់ជួលបានទំនាក់ទំនងឲ្យរូបខ្លួនយកលុយទៅសល់ម៉ូតូប្រគល់ឲ្យទៅជនរងគ្រោះវិញដែលជនរងគ្រោះបានយកទៅដាក់បញ្ចាំនៅម្តុំផ្សារឃ្លាំងរំសេវហើយរូបខ្លួនរួមទាំងសមត្ថកិច្ចកងរាជអាវុធហត្ថ និងជនរងគ្រោះបានទៅលស់យកម៉ូតូពីកន្លែងបញ្ចាំ និងយកមកធ្វើការប្រគល់ទទួលម៉ូតូឲ្យជនរងគ្រោះវិញនៅកន្លែងសមត្ថកិច្ចដោយមានកំណត់ហេតុនិងបានថតរូបប្រគល់ទទួលម៉ូតូរវាងខ្លួននិងជនរងគ្រោះនៅចំពោះមុខសមត្ថកិច្ចផងដែរ។ក្រោយពីប្រគល់ទទួលម៉ូតូរួចជនរងគ្រោះបានយកម៉ូតូជិះដឹកគ្នាចេញទៅមិនដឹងរស់នៅទីកន្លែងណាទេចំណែកខ្លួនត្រឡប់មកផ្ទះវិញជនរងគ្រោះទាំងប្តីប្រពន្ធបានប្រាប់ខ្លួនថាពេលទទួលបានម៉ូតូជិះធ្វើការវិញហើយពួកគាត់សន្យាមិនប្តឹងទាមទារអ្វីទៀតទេសុំបញ្ចប់រឿងត្រឹមនេះ។

-តុលាការអានរបាយការណ៍សរុបលេខ ១៣៤/២១ រ.ប.ក ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២១ របស់ការិយាល័យព្រហ្មទណ្ឌ នៃកងរាជអាវុធហត្ថរាជធានីភ្នំពេញ បានសន្និដ្ឋានថា៖ ឈ្មោះ [redacted] **ថារ៉ា** (ឃាត់ខ្លួន) ពិតជាមានពិរុទ្ធភាពក្នុងការប្រព្រឹត្តអំពើ **កំហែងយកទ្រព្យ** ពិតប្រាកដមែន។

សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

ក្រោយពីបានធ្វើការសួរដេញដោល និងពិនិត្យភស្តុតាងក្នុងសំណុំរឿងរួចមកឃើញថា:ជនជាប់ចោទឈ្មោះ [redacted] **ថារ៉ា** ភេទប្រុស អាយុ៣០ឆ្នាំ ប្រព្រឹត្តអំពើ **កំហែងយក** (**ប្រាក់**) ពិតប្រាកដមែន។ ដូច្នេះតំណាងអយ្យការសុំតម្កល់ដីកាសន្និដ្ឋានស្តាពរទុកជាបានការដដែល និងសុំឲ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមច្បាប់។

សេចក្តីសន្និដ្ឋានប្តឹងសុំរបស់មេធាវីការពារសិទ្ធិជនជាប់ចោទ

- មេធាវី [redacted]

អត្តលេខ [redacted] ជាមេធាវីការពារសិទ្ធិឲ្យជនជាប់ចោទឈ្មោះ [redacted] **ថារ៉ា** ខាងលើ បានធ្វើសេចក្តីសន្និដ្ឋានថា៖ ក្រោយពីបានធ្វើការសួរដេញដោល និងពិនិត្យភស្តុតាងក្នុងសំណុំរឿងរួច មកឃើញថា: កូនក្តីរបស់ខ្លួនឈ្មោះ [redacted] **ថារ៉ា** ពុំបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ហេតុនេះស្នើរសុំរក្សាទុកដូចមានក្នុងសេចក្តីសន្និដ្ឋានការពារចុះថ្ងៃទី ០៧-០២-២០២២។

សំដីចុងក្រោយរបស់ជនជាប់ចោទ

ជនជាប់ចោទឈ្មោះ [redacted] **ថារ៉ា** បានសុំឲ្យតុលាការសម្រេចឲ្យខ្លួនរួចផុតពីបទចោទប្រកាន់។

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់មេធាវីការពារសិទ្ធឲ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យឯកសារភស្តុតាងនានា

-ក្រោយពីបានពិនិត្យ និងពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

សំអាងហេតុ

១.តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៥១៩៥ (ច) ដ.ដ ចុះថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០២១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញ បានបញ្ជូនមកជំនុំជម្រះលើជនជាប់ចោទឈ្មោះ [redacted] **ថារ៉ា** ភេទប្រុស អាយុ ៣០ ឆ្នាំ ពីបទៈ **កំហែងយក** (ទ្រាក់) ប្រព្រឹត្តនៅចំណុចបន្ទប់ជួលភូមិដំណាក់ដំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៦៣ និងមាត្រា ៣៦៤ នៃក្រមព្រហ្មទណ្ឌ។

២.តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ [redacted] **ណេត** បានឆ្លើយថា: កាលពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១ វេលាម៉ោង ២៣ និង ៣០ នាទី នៅចំណុចបន្ទប់ដែលខ្លួនជួលស្នាក់ ស្រាប់តែមានក្មេងប្រុសម្នាក់មកគោះទ្វារបន្ទប់របស់ខ្លួនព្រមជាមួយគ្នានោះក៏មានជនមួយក្រុមមានគ្នាប្រហែល ០៧ នាក់ (ប្រុស) បានធាក់ទ្វារបន្ទប់ខ្លួនទម្លុះចូល និង សុំឆែកឆេរដែលនៅក្នុងចំណោមនោះខ្លួនបានឃើញក្មេងប្រុសម្នាក់ជាប់ខ្មោះផងដែរ ហើយក្នុងជនមួយក្រុមនោះ ខ្លួនបាន ស្គាល់ចំនួន ០៣ នាក់ រួមមានឈ្មោះ [redacted] **ឈឿន** (សន្តិសុខយាមផ្ទះជួលនោះ) ឈ្មោះ **ភ័ក្រ** (សន្តិសុខផ្ទះជួលនោះ) និង ឈ្មោះ **រ៉ា** ភេទប្រុសស្លៀកពាក់ស៊ីវិល (តាំងខ្លួនជាអាវុធហត្ថ)។ បន្ទាប់មកឈ្មោះ **រ៉ា** បានបញ្ជាឱ្យឈ្មោះ **ភ័ក្រ** ដាក់ខ្មោះប្តី របស់ខ្លួនឈ្មោះ [redacted] **កុសល** ហើយរុញចេញក្រៅបន្ទប់ រួចយកក្រាមពណ៌សថ្នាមួយកញ្ចប់តូចចេញពីហោប៉ៅខោក្មេងប្រុសនោះ មកដាក់នៅមុខប្តីរបស់ខ្លួន និងឱ្យប្តីខ្លួនកាន់ថែមទាំងថតរូបទុកជាភស្តុតាង។ ក្រោយមកឈ្មោះ រ៉ា បានបង្ខំពួកខ្លួនឱ្យរកលុយ ឱ្យគាត់ចំនួន ៥០០ ដុល្លារ ដើម្បីបញ្ចប់រឿងដោយគំរាមកំហែងថា បើមិនឱ្យលុយទេ គាត់នឹងយកប្តីខ្លួនដាក់គុក ពេលនោះខ្លួន គ្មានលុយទេ ប៉ុន្តែដោយសារខ្លួនភ័យខ្លាចខ្លាំងពេក ខ្លួនក៏យល់ព្រមឱ្យពួកគាត់ (ឈ្មោះ រ៉ា និងបក្ខពួក) ជូនខ្លួនយកម៉ូតូរបស់ខ្លួន ម៉ាកហុងដា សេ១២៥ ពណ៌ខ្មៅ ស្លាកលេខ ភ្នំពេញ ៩៣៣៤ ទៅបញ្ចាំនៅម្តុំផ្សារឃ្លាំងរំសេវ ហើយខ្លួនត្រូវបានបង្ខំឱ្យចូលទៅបញ្ចាំយកប្រាក់ចំនួន ៦៦០ ដុល្លារ សរុបទាំងការប្រាក់។ ក្រោយពេលបញ្ចាំម៉ូតូបានប្រាក់ឈ្មោះ រ៉ា និងឈ្មោះ **ភ័ក្រ** បានយកប្រាក់រួចក៏ប្រគល់ប្រាក់ឱ្យខ្លួនចំនួន ១០០ ដុល្លា ដើម្បីបង់ថ្លៃផ្ទះជួល ហើយបង្គាប់ឱ្យពួកខ្លួនរើឥវ៉ាន់ចេញពីបន្ទប់ជួល ឱ្យឈប់ជួល នៅទីនោះ បន្ទាប់មកពួកគាត់ក៏ជិះម៉ូតូភីស៊ីអិច គេចខ្លួនបាត់ដោយបន្សល់ទុកនូវម៉ូតូមួយគ្រឿងម៉ាកអ៊ីមអេស អិច។ ចំពោះឈ្មោះ [redacted] **ឈឿន** នៅពេលគាត់បានចូលរួមឆែកឆេរបន្ទប់ដែរនោះ គាត់ពុំបានគំរាមកំហែង និងគំរាមយក ប្រាក់ពីខ្លួនឡើយ។

៣.តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] **ហឿន ហៅតាឃ្លោក** បានឆ្លើយថា: ខ្លួនតែងបានឃើញឈ្មោះ [redacted] ថារ៉ា ភេទប្រុសដើរមើលការខុសត្រូវ ក្នុងផ្ទះជួលកន្លែងកើតហេតុមិនដឹងគាត់ធ្វើការងារអ្វីទេហើយក៏មិនដឹងថាត្រូវជាអ្វីជាមួយម្ចាស់បន្ទប់ជួលនោះទេ។ នៅពេលរឿងហេតុកើតឡើងកាលពីយប់ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១ នៅបន្ទប់ជួលភូមិដំណាក់ធំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ខ្លួនមិនបានដឹងទេ។ នៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២១ ម៉ោង៣ជាងរសៀលម្ចាស់បន្ទប់ជួលបាន ទំនាក់ទំនងឱ្យរូបខ្លួនយកលុយទៅសល់ម៉ូតូប្រគល់ឱ្យទៅជនរងគ្រោះវិញដែលជនរងគ្រោះបានយកទៅដាក់បញ្ចាំនៅម្តុំផ្សារឃ្លាំងរំសេវហើយរូបខ្លួនរួមទាំងសមត្ថកិច្ចកងរាជអាវុធហត្ថ និងជនរងគ្រោះបានទៅលស់យកម៉ូតូពីកន្លែងបញ្ចាំ និងយកមកធ្វើការប្រគល់ទទួលម៉ូតូឱ្យជនរងគ្រោះវិញនៅកន្លែងសមត្ថកិច្ចដោយមានកំណត់ហេតុនិង បានថតរូបប្រគល់ទទួលម៉ូតូរវាងខ្លួននិងជនរងគ្រោះនៅចំពោះមុខសមត្ថកិច្ចផងដែរ។ ក្រោយពីប្រគល់ទទួលម៉ូតួរួចជនរងគ្រោះបានយកម៉ូតូជិះដឹកគ្នាចេញទៅមិន ដឹងរស់នៅទីកន្លែងណាទេចំណែកខ្លួនត្រឡប់មកផ្ទះវិញជនរងគ្រោះទាំងប្តីប្រពន្ធបានប្រាប់ខ្លួនថាពេលទទួលបានម៉ូតូជិះធ្វើការវិញហើយពួកគាត់សន្យាមិនប្តឹងទាមទារអ្វីទៀតទេសុំបញ្ចប់រឿងត្រឹមនេះ។ ៣

៤.តាមរបាយការណ៍សរុបលេខ ១៣៤/២១ រ.ប.ក ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២១ របស់ការិយាល័យ ព្រហ្មទណ្ឌ នៃកងរាជអាវុធហត្ថរាជធានីភ្នំពេញ បានសន្និដ្ឋានថា៖ ឈ្មោះ [redacted] **ថារ៉ា** (ឃាត់ខ្លួន) ពិតជាមានពិរុទ្ធភាពក្នុងការ ប្រព្រឹត្តអំពើ **កំហែងយកទ្រាក់** ពិតប្រាកដមែន។

៥.តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted]**ថារ៉ា** បានឆ្លើយបដិសេធថា: ខ្លួនមិនមែនជាមន្ត្រី ឬបានតាំងខ្លួនជាមន្ត្រីកងរាជអាវុធហត្ថនោះទេខ្លួន ជាពលរដ្ឋធម្មតាប៉ុណ្ណោះ។ ខ្លួនមិនកំហែងយក(ប្រាក់) ពីជនរងគ្រោះ នៅចំណុចបន្ទប់ជួលភូមិដំណាក់ធំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១ នៅវេលាម៉ោង ១១:៣០ យប់ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១ នោះទេ។ មានមនុស្សប្រុសម្នាក់មិនស្គាល់ឈ្មោះពាក់អាវ ខ្មៅវាលក្លៀកដើរចូលមកបន្ទប់ជួលកន្លែងកើតហេតុហើយសន្តិសុខឈ្មោះ លឿន, ឈ្មោះ ភ័ក្រ រួមទាំងរូបខ្លួនដែលយាមនៅទីតាំងកន្លែងកើតហេតុនេះឃើញ ក៏ដេញតាមចាប់បានឆែកឃើញកញ្ចប់បារី១ ក្នុងនោះមាន កញ្ចប់គ្រឿងញៀន១កញ្ចប់ ខ្លួនក៏សួរថាបានមកពីណា? យក ទៅណា? បុរសមិនស្គាល់ឈ្មោះនោះប្រាប់ថាយកមកពីឈ្មោះ **សិត** ហើយប្រាប់ថាយកទៅឲ្យគេ និងប្រាប់ទៀតថាបន្តិចទៀតមានគេមកយកនៅក្រៅរបងបន្ទប់ជួលហើយ។ ខ្លួន និង សន្តិសុខឈ្មោះ **លឿន**, ឈ្មោះ **ភ័ក្រ** ក៏នាំបុរសមិនស្គាល់ឈ្មោះទៅបន្ទប់ជួល របស់ឈ្មោះសិតស្នាក់នៅ ដើម្បីសាកសួរបុរស មិនស្គាល់ឈ្មោះអះអាងថាខ្លួនបានទិញថ្នាំញៀនពីឈ្មោះ**សិត** ទើបពួកខ្លួនសម្រេចនាំបុរសមិនស្គាល់ឈ្មោះទៅបន្ទប់ជួលរបស់ឈ្មោះសិតដើម្បីបញ្ជាក់ការពិត។ ពេលមកដល់បន្ទប់ជួលឈ្មោះ សិតបានបដិសេធថាមិនបានលក់ថ្នាំញៀនឲ្យបុរសមិនស្គាល់ ឈ្មោះនេះទេ។ នៅពេលនោះប្តីប្រពន្ធជនរងគ្រោះឈ្មោះ **សិត** បានសំណូមពរកុំឲ្យមានរឿងពាក់ព័ន្ធលើការទិញលក់ថ្នាំញៀន បានសុំសំរួលផ្តល់ប្រាក់ឲ្យទៅពួកសន្តិសុខដែលយាមនៅបន្ទប់ជួលដែលពួកគេស្នាក់នៅពិតមែនតែខ្លួនមិនបានដឹងឮរឿងនេះ ទេ។ ប្រាក់ដែលជនរងគ្រោះផ្តល់ឲ្យសន្តិសុខផ្តល់ឲ្យនោះខ្លួនមិនបាន បង្ខិតបង្ខំ ឬ គំរាមកំហែងពួកគាត់ផ្តល់ប្រាក់មកឲ្យសន្តិសុខនិងខ្លួននោះទេ។ក្រៅពីរូបខ្លួននិងសន្តិសុខឈ្មោះ **លឿន**, ឈ្មោះ **ភ័ក្រ** ខ្លួនមិនមានបក្ខពួកផ្សេងទេ។

ចម្លើយបដិសេធរបស់ជនជាប់ចោទខាងលើ ពុំមានភស្តុតាងអ្វីបញ្ជាក់ទេ តុលាការយល់ឃើញថា ចម្លើយនេះ គ្រាន់តែជាការឆ្លើយដោះសារ ដើម្បីចង់គេចពីការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើប្រព្រឹត្តរបស់ខ្លួនតែប៉ុណ្ណោះ។ ផ្ទុយទៅវិញ ផ្អែកតាមរបស់ជនរងគ្រោះឈ្មោះ [redacted]**ណេត** , ចម្លើយសាក្សីឈ្មោះ [redacted]**ហឿន** ហៅ **តាឃ្លោក** និងតាមរបាយការណ៍សរុបលេខ ១៣៤/២១ រ.ប.ក ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២១ របស់ការិយាល័យព្រហ្មទណ្ឌ នៃកងរាជអាវុធហត្ថរាជធានីភ្នំពេញ បញ្ជាក់បានថា: ឈ្មោះ [redacted]**ថារ៉ា** ភេទប្រុស អាយុ ៣០ ឆ្នាំ ពិតជាបានប្រព្រឹត្តអំពើ **កំហែងយក** (**ទ្រាក់**) ប្រព្រឹត្តនៅចំណុចបន្ទប់ជួលភូមិដំណាក់ដំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានី ភ្នំពេញ កាលពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១ ប្រាកដមែន។

៦.អំពើរបស់ជនជាប់ចោទឈ្មោះ [redacted]**ថារ៉ុ** បានធ្វើឲ្យប៉ះពាល់ដល់សន្តិសុខសណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈក្នុងសង្គម និងជាពិសេសប៉ះពាល់ដល់ទ្រព្យសម្បត្តិរបស់អ្នកដទៃហើយច្បាប់ព្រហ្មទណ្ឌបានការពារដោយបញ្ញត្តិជាបទ: **កំហែងយក** (**ទ្រាក់**) តាមបញ្ញត្តិមាត្រា ៣៦៣ មាត្រា៣៦៤ នៃក្រមព្រហ្មទណ្ឌ។

៧.ជនជាប់ចោទឈ្មោះ [redacted]**ថារ៉ា** ភេទប្រុស អាយុ ៣០ ឆ្នាំ **ជាន់តិចន** មានស្មារតីដឹងខុសត្រូវច្បាស់លាស់លើអំពើប្រព្រឹត្តរបស់ខ្លួនចំពោះមុខច្បាប់ ហើយពុំមានភស្តុតាងណាមួយបញ្ជាក់ថាជននេះមានវិបល្លាសផ្នែកស្មារតីដែលនាំឲ្យអាចរួចផុត ឬបន្ថយការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌទេ។

៨. មានភស្តុតាង និងពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] **ថាវ៉ា** ពីបទ: **កំហែងយកទ្រព្យ** (ទ្រង់ទ្រាយ) ប្រព្រឹត្តនៅចំណុចបន្ទប់ជួលភូមិដំណាក់ដំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៦៣ និងមាត្រា ៣៦៤ នៃក្រមព្រហ្មទណ្ឌ។

៩. ជនរងគ្រោះមិនបានចូលមកតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅមុខចៅក្រមស៊ើបសួរ និងនៅពេលសវនាការទេ។ គប្បីតុលាការមិនពិចារណាអំពីសំណងឡើយ។

១០.តំណាងអយ្យការសន្និដ្ឋានសុំតម្កល់ដីកាបញ្ជូនស្ថានទុកនៅដដែល និងសុំឲ្យតុលាការសម្រេចផ្តន្ទាទោសជនជាប់ចោទតាមកំណត់ច្បាប់។ ចំណុចនេះ យើងបានពិចារណារួចហើយ។

១១.មេធាវីការពារសិទ្ធិជនជាប់ចោទឈ្មោះ [redacted] **ថាវ៉ា** បានសន្និដ្ឋានសុំឲ្យតុលាការសម្រេចឲ្យកូនក្តីខ្លួនរួចផុតពីបទចោទប្រកាន់។ ចំណុចនេះ យើងបានពិចារណារួចហើយ។

១២.ជនជាប់ចោទឈ្មោះ [redacted] **ថាវ៉ា** បានសន្និដ្ឋានសុំឲ្យតុលាការសម្រេចឲ្យកូនក្តីខ្លួនរួចផុតពីបទចោទប្រកាន់។ ចំណុចនេះ យើងបានពិចារណារួចហើយ។

ហេតុដូច្នេះសាលាដំបូងរាជធានីភ្នំពេញ
សិនិច្ឆ័យសេចក្តី

-ផ្តន្ទាទោសលើជនជាប់ចោទឈ្មោះ [redacted]**ថាវ៉ា** ភេទប្រុស អាយុ ៣០ ឆ្នាំ ជនជាតិ ខ្មែរ ដាក់ពន្ធនាគារកំណត់ រយៈពេល ០២ (ពីរ) ឆ្នាំ តែទោសនេះត្រូវអនុវត្ត ក្នុងពន្ធនាគារកំណត់ត្រឹមថៃរៈវេលាដែលបានឃុំខ្លួនបណ្តោះអាសន្ន ទោសដែលនៅសល់ត្រូវអនុវត្តទោសព្យួរធម្មតា។

ពីបទ: **កំហែងយកទ្រព្យ** (ទ្រង់ទ្រាយ) ប្រព្រឹត្តនៅចំណុចបន្ទប់ជួលភូមិដំណាក់ដំ សង្កាត់ស្ទឹងមានជ័យ ខណ្ឌមានជ័យ រាជធានី ភ្នំពេញ កាលពីថ្ងៃទី២៥ ខែសីហា ឆ្នាំ២០២១ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៦៣ និងមាត្រា ៣៦៤ នៃក្រមព្រហ្មទណ្ឌ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១០ ខែកុម្ភៈឆ្នាំ២០២២ ចំពោះមុខជនជាប់ចោទ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២២ ។

បើកផ្លូវប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

ក្រឡាបញ្ជី

ហត្ថលេខា និងត្រា

[redacted]

ចៅក្រមជំនុំជម្រះ

ហត្ថលេខា និងត្រា

[redacted]

បានឃើញ

ចៅក្រម

[redacted]

" បានចម្លងត្រឹមត្រូវតាមច្បាប់ដើម "

ថ្ងៃ ព្រហស្បតិ៍ ១ រោច ខែ មាឃ ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៥

រាជធានីភ្នំពេញ , ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០២២

ក្រឡាបញ្ជី

[redacted]